# គណបក្ស សម រង្ស៊ី
SAM RAINSY PARTY
PARTI SAM RAINSY
**សីលធម៌ សច្ចធម៌ យុត្តិធម៌**

# របាយការណ៍
## ស្តីពី
## សកម្មភាពសំខាន់ៗរបស់គណបក្ស សម រង្ស៊ី
*(ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥)*

ចាប់តាំងពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ គណបក្ស សម រង្ស៊ី មានសកម្មភាពសំខាន់ៗដូចតទៅ :

**I - សកម្មភាពទូទៅរបស់គណបក្ស**

១-ការងារការផ្តល់ប័ណ្ណគណបក្សដល់សមាជិកថ្មី :

នៅឆ្នាំ២០០៥នេះ គណបក្សបានផ្តល់ប័ណ្ណសមាជិកគណបក្សជូនប្រជាពលរដ្ឋខ្មែរ ដែលសុំចូលជាសមាជិកគណបក្ស បានចំនួន៣៥២០៦នាក់ ក្នុងនោះ ប្រុស១៧៨៥០នាក់ និងស្រី១៧៣៥៦នាក់ ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ គណបក្ស សម រង្ស៊ី បានផ្តល់ប័ណ្ណសមាជិកគណបក្សសរុបចំនួន៦០៩១០៤នាក់ ។

២-ការងារបណ្តុះបណ្តាល :

-គណបក្សបានសហការជាមួយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ សំរាប់កិច្ចការអន្តរជាតិ (NDI) បើកវគ្គបណ្តុះបណ្តាលសំរាប់មន្ត្រីគណបក្ស សម រង្ស៊ី ថ្នាក់មូលដ្ឋាន ស្តីពី "កំណែទំរង់របនាសម្ព័ន្ធគណបក្សមូលដ្ឋាន និងខេត្ត-ក្រុង" បានចំនួន១៦វគ្គ ដែលប្រព្រឹត្តទៅនៅទូទាំងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិក្ខាកាមចូលរួមចំនួន១៦៧៥នាក់ ។

-គណបក្សបានសហការជាមួយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ សំរាប់កិច្ចការអន្តរជាតិ (NDI) បើកវគ្គបណ្តុះបណ្តាលសំរាប់ថ្នាក់ដឹកនាំចលនាយុវជនជាតិខ្មែរនៃគណបក្ស សម រង្ស៊ី ស្តីពី "កិច្ចប្រជុំក្រុមយុវជនក្នុងភាពជាអ្នកដឹកនាំ" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការអង្គការ **World Vision** ភ្នំពេញ ដោយមានសិក្ខាកាមជាថ្នាក់ដឹកនាំចលនាយុវជនជាតិខ្មែរចូលរួមចំនួន១០នាក់ ។

-គណបក្សបានសហការជាមួយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ សំរាប់កិច្ចការអន្តរជាតិ (NDI) បើកវគ្គបណ្តុះបណ្តាលសំរាប់ថ្នាក់ដឹកនាំចលនាស្ត្រីជាតិខ្មែរនៃគណបក្ស សម រង្ស៊ី ស្តីពី "កិច្ចប្រជុំក្រុម



ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org

ស្ត្រីក្នុងភាពជាអ្នកដឹកនាំ" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការអង្គការ **World Vision** ភ្នំពេញ ដោយមានសិក្ខាកាមជាថ្នាក់ដឹកនាំចលនាស្ត្រីជាតិខ្មែរចូលរួមចំនួន១៥នាក់ ។

-គណបក្សបានសហការជាមួយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ (**IRI**) បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ បានចំនួន២វគ្គ ដែលប្រព្រឹត្តទៅនៅសណ្ឋាគារសាន់វេ ក្រុងភ្នំពេញ ដោយមានសិក្ខាកាមចូលរួមចំនួន៦៥នាក់ ។

-គណបក្សបានសហការជាមួយមូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Foundation) និងអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ (BFD) បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់នៃគណបក្ស សម រង្ស៊ី បានចំនួន៥វគ្គ ដែលមានសិក្ខាកាមចូលរួមក្នុងមួយវគ្គៗចំនួន៣០នាក់ ។

-គណបក្សបានសហការជាមួយមូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Foundation) បើកវគ្គបណ្តុះបណ្តាលសំរាប់អ្នកតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្ស សម រង្ស៊ី ស្តីពី "សភាប្រជាធិបតេយ្យ" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលគណបក្សក្រុងភ្នំពេញ ដោយមានសិក្ខាកាមចូលរួមចំនួន៤៥នាក់ ។

-គណបក្សបានសហការជាមួយមូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Foundation) បើកវគ្គបណ្តុះបណ្តាលសំរាប់មន្ត្រីថ្នាក់ដឹកនាំ នៃគណបក្ស សម រង្ស៊ី ស្តីពី "សភាប្រជាធិបតេយ្យ" ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាលគណបក្សក្រុងភ្នំពេញ ដោយមានសិក្ខាកាមចូលរួមចំនួន៦០នាក់ ។

-គណបក្សបានសហការជាមួយអង្គការ Friedrich Naumann Foundation បើកវគ្គបណ្តុះបណ្តាលសំរាប់អ្នកតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំគណបក្ស ស្តីពី "ការរៀបចំយុទ្ធសាស្ត្រនយោបាយរបស់គណបក្ស" ដែលប្រព្រឹត្តទៅនៅសណ្ឋាគារសាន់វេ ក្រុងភ្នំពេញ ដោយមានសិក្ខាកាមចូលរួមចំនួន៣៥នាក់ ។

-គណបក្សបានបើកវគ្គបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នៃគណបក្ស សម រង្ស៊ី និងថ្នាក់ដឹកនាំគណបក្ស សម រង្ស៊ី ថ្នាក់មូលដ្ឋាន នៅទូទាំងប្រទេស ស្តីពី "ការគ្រប់គ្រងជំលោះ និងដំណោះស្រាយ" បានចំនួន៩លើក ដោយមានសិក្ខាកាមចូលរួមសរុបចំនួន១១០៦នាក់ ។

## ៣-<u>ការងារការពារសិទ្ធិមនុស្ស</u> :

ក្នុងរយៈពេលមួយឆ្នាំនេះ ថ្នាក់ដឹកនាំគណបក្ស ក៏ដូចថ្នាក់ដឹកនាំក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង បានចុះដោះស្រាយបញ្ហាការរំលោភសិទ្ធិមនុស្សបានជាច្រើនករណី ហើយជាមួយគ្នានេះដែរ គណបក្សបានដាក់ពាក្យបណ្តឹងទៅអង្គការសិទ្ធិមនុស្ស និងអាជ្ញាធរមានសមត្ថកិច្ចចំនួន១១ករណី ក្នុងនោះមាន៦ករណីជាឃាតកម្មនយោបាយ, ៣ករណីជាការប៉ុនប៉ងធ្វើឃាត និង២ករណីជាការគំរាមកំហែងបំភិតបំភ័យ ។

## ៤-<u>ការងាររៀបចំពិធីផ្សេងៗ</u> :

ក្នុងឆ្នាំ២០០៩នេះ គណបក្ស សម រង្ស៊ី បានរៀបចំពិធីធំៗដូចតទៅ :

_នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ គណបក្សបានរៀបចំពិធីអបអរសាទរខួបកំណើតឆ្នាំទី៧ របស់ចលនាយុវជនជាតិខ្មែរ នៅភោជនីយដ្ឋានបឹងលីនណែរ ក្រុងភ្នំពេញ ។

_នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៥ គណបក្សបានរៀបចំពិធីអបអរសាទរទិវានារីអន្តរជាតិ៨ មីនា និងអបអរសាទរខួបកំណើតឆ្នាំទី៧ របស់ចលនាស្ត្រីជាតិខ្មែរ នៅភោជនីយដ្ឋានសាមគ្គី ក្រុងភ្នំពេញ ។

_នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ គណបក្ស និងក្រុមគ្រួសារជនរងគ្រោះបានប្រារព្ធធ្វើពិធីបុណ្យខួបឆ្នាំទី៨នៅមុខចេតីយ៍ជនរងគ្រោះមុខមន្ទីររដ្ឋសភា ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះ ដែលបានបាត់បង់ជីវិតដោយអំពើភេរវកម្មនៃការវាយប្រហារដោយគ្រាប់បែកដៃ មកលើបាតុកររអហិង្សា មុខមន្ទីររដ្ឋសភាកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ។

_នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ គណបក្សបានប្រារព្ធពិធីបុណ្យបង្សុកូលគោរពវិញ្ញាណក្ខន្ធជនរងគ្រោះដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅទីស្នាក់ការកណ្តាលគណបក្ស ភ្នំពេញ ។

_នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ គណបក្សបានប្រារព្ធពិធីបុណ្យបង្សុកូលរំលឹកវិញ្ញាណក្ខន្ធអ្នកដែលបានបាត់បង់ជីវិតនៅក្នុងនិងក្រោយថ្ងៃរដ្ឋប្រហារ៥-៦ កក្កដា ឆ្នាំ១៩៩៧ នៅមុខចេតីយ៍ជនរងគ្រោះមុខមន្ទីររដ្ឋសភា ។

_នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៥ គណបក្សបានប្រារព្ធពិធីបុណ្យបង្សុកូលនៅមុខមន្ទីររដ្ឋសភា ដើម្បីរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ ដែលបានបាត់បង់ជីវិតដោយការបង្ក្រាបរបស់អាជ្ញាធរ មកលើបាតុកររអហិង្សាប្រឆាំងលទ្ធផលបោះឆ្នោតឆ្នាំ១៩៩៨ ។

_នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ គណបក្ស សម រង្ស៊ី បានប្រារព្ធពិធីកាន់ទុក្ខនៅទីស្នាក់ការកណ្តាលគណបក្សក្រុងភ្នំពេញ ចំពោះការបាត់បង់សិទ្ធិរបស់កម្ពុជាលើទឹកដីដែលពួកអាណានិគមបារាំង និងពួកវៀតណាមឈ្លានពានបានកាត់យកទៅ ហើយបានព្រមព្រៀង ដោយអំណាចរណប និងអសមត្ថភាពនៅកម្ពុជា នាពេលកន្លងមកនេះ ។

_នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ គណបក្សបានរៀបចំពិធីរំលឹកខួបឆ្នាំទី១០ ថ្ងៃបង្កើតគណបក្ស សម រង្ស៊ី (អតីតគណបក្សជាតិខ្មែរ) នៅទីស្នាក់ការកណ្តាលគណបក្សក្រុងភ្នំពេញ ។

## II - សកម្មភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្ស

### ១-សកម្មភាពនៅក្នុងប្រទេស :

ក្នុងរយៈពេលមួយឆ្នាំនេះ ក្រៅពីសកម្មភាពការទូត, ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្ស. អ្នកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភារបស់គណបក្ស សម រង្ស៊ី បានជួយការពារ និងធ្វើអន្តរាគមន៍ដល់ជនរងគ្រោះ

បានសុំព្រះរាជអន្តរាគមន៍ពីព្រះមហាក្សត្រ សុំព្រះអង្គជួយដល់ប្រជាពលរដ្ឋដែលខ្វះស្បៀងអាហារ ដោយសារគ្រោះរាំងស្ងួត និងខ្វះដីធ្លីធ្វើស្រែចំការ ។

ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំជាន់ខ្ពស់ និងសមាជិកសភាទាំងពីររបស់គណបក្ស សម រង្ស៊ី បានចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងសកម្មជនគណបក្សនៅតាមមូលដ្ឋានជាប់ជាប្រចាំ ដូចជា :

-នៅខែមករា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តកំពង់ចាម និងខេត្តបាត់ដំបង ។

-នៅខែមករា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះដោះស្រាយបញ្ហាទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋនៅភូមិកោះរាម ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង ។

-នៅខែកុម្ភៈ ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពត ខេត្តពោធិសាត់ និងរាជធានីភ្នំពេញ ។

-នៅខែមីនា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តបន្ទាយមានជ័យ ។

-នៅខែមេសា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តតាកែវ ។

-នៅខែឧសភា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តតាកែវ ។

-នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៤ គណបក្សបានធ្វើបុណ្យផ្ការស្មីសាមគ្គី ដើម្បីប្រមូលបច្ច័យយកទៅកសាងខ្លោងទ្វារវត្តបាលីចាស់ ស្ថិតនៅភូមិអន្ទោងខ្វែង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ។

-នៅខែមិថុនា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្សនៅខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ ។

-នៅខែកក្កដា ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្ស

-នៅខែធ្នូ ថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សបានចុះសួរសុខទុក្ខប្រជារាស្ត្រ និងសកម្មជនគណបក្ស នៅខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តបាត់ដំបង ក្រុងព្រះសីហនុ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងក្រុងប៉ៃលិន ។

២-<u>សកម្មភាពនៅក្រៅប្រទេស</u> :

-នៅខែសីហា និងខែកញ្ញា លោកប្រធាន សម រង្ស៊ី បានដឹកនាំប្រតិភូជាន់ខ្ពស់គណបក្សទៅបំពេញបេសកកម្មនៅសហរដ្ឋអាមេរិក និងប្រទេសកាណាដា ដើម្បីជួបសំណេះសំណាលជាមួយសហគមន៍ខ្មែរ និងថ្នាក់ដឹកនាំសាខាគណបក្ស សម រង្ស៊ី ប្រចាំសហរដ្ឋអាមេរិក និងកាណាដា ។

-នៅថ្ងៃទី១៥ ខែវិច្ឆិកា គណបក្សបានបើកការប្រជុំមួយនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្រោមអធិបតីភាពលោកប្រធាន សម រង្ស៊ី ស្ដីអំពីស្ថានការណ៍នយោបាយបច្ចុប្បន្ន និងកំណែទំរង់រចនាសម្ព័ន្ធគណបក្សថ្នាក់មូលដ្ឋាន ដោយមានការចូលរួមពីអ្នកតំណាងរាស្ត្រ និងសមាជិកគណៈកម្មាធិការនាយកគណបក្ស សម រង្ស៊ី ចំនួន៣៤រូប ។

-នៅខែធ្នូ ថ្នាក់ដឹកនាំគណបក្សបានទៅបំពេញបេសកកម្មនៅប្រទេសបារាំង ដើម្បីជួបសំណេះសំណាលជាមួយសហគមន៍ខ្មែរ និងថ្នាក់ដឹកនាំសាខាគណបក្សប្រចាំប្រទេសបារាំង ៕

*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥*

**អគ្គលេខាធិការស្ដីទី**

ម៉េង រីតា

បានឃើញ និង ឯកភាព

ប្រធានគណបក្សស្ដីទី

គង់ គាំ